# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សេចក្តីសម្រេចកែសម្រួលលើកទី១ លើឯកសារអាជ្ញាប័ណ្ណរួមលេខ ០៣១ឯអ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ សំរាប់ លោក ចាន់ ថុន ធ្វើសេវាកម្មផលិតនិងចែកចាយអគ្គិសនីនៅទីរួមខេត្តព្រះវិហារ សម្រាប់ការផ្លាស់ប្តូរនិងបន្ថែមម៉ាស៊ីនភ្លើង

## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៣១ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យលោក ចាន់ ថុន នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំផ្លាស់ប្តូរ និងបន្ថែមម៉ាស៊ីនភ្លើងរបស់លោក ចាន់ ថុន ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦

-យោងសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អំពីការស្នើសុំផ្លាស់ប្តូរឬបន្ថែមមធ្យោបាយផលិតកម្មរបស់សេវាករអគ្គិសនីតូចៗលេខ ០៦២លទ-០៣ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៣

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៦ ដល់ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៦

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៩៥ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧

## សម្រេច

### ប្រការ១

កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៣១ឯអ ដែលបានចេញឱ្យ **លោក ចាន់ ថុន** នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ (បន្ទាប់ពីនេះទៅហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") ដើម្បីផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើការផ្លាស់ប្តូរ និងបន្ថែមម៉ាស៊ីនភ្លើង ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់នៅទីរួមខេត្តព្រះវិហារដូចខាងក្រោម:

-ធ្វើការផ្លាស់ប្តូរម៉ាស៊ីនភ្លើងពីអនុភាព ១០០គ.វ.អ មក ២០០គ.វ , ៣០០គ.វ.អ មក ៣២០គ.វ, ៧៥គ.វ.អ មក ១០០គ.វ និង ១០០គ.វ.អ មក ១០០គ.វ ។

-ធ្វើការបន្ថែមម៉ាស៊ីនភ្លើងចំនួន១គ្រឿង ដែលមានអនុភាព ២៥០គ.វ ។

### ប្រការ២

ឧបសម្ព័ន្ធទី២ចាស់របស់ឯកសារអាជ្ញាប័ណ្ណលេខ ០៣១ឯអ និងត្រូវបានជំនួសដោយឧបសម្ព័ន្ធទី២ថ្មី ដែលមានភ្ជាប់មកជាមួយនេះ ។

**ប្រការ៣**

សេចក្ដីសម្រេចនេះនិង ឧបសម្ព័ន្ធទី២កែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ០៣១ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៣១ឯអ និងខ្លឹមសារដែលបានកែសម្រួលរួចហើយត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្ដីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ញើសេចក្ដីសម្រេចនេះទៅតម្កល់ទុកបន្ថែម នៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ០៣១ឯអបានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៣១ឯអ ដែលដម្កល់ទុក មានការកែសម្រួលជាថ្មីស្របតាមសេចក្ដីសម្រេចនេះ ។

ភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

## ឧបសម្ព័ន្ធទី២
## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា
## លើកទី ៩៥ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧
## មធ្យោបាយផលិតកម្មដែលមានស្រាប់

### មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

#### ក. រោងម៉ាស៊ីន

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតនៅទីរួមខេត្តព្រះវិហារ ។

#### ខ. លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៥គ្រឿង ដែលមានអានុភាព តម្លើងសរុប 970 kW គឺ:

- ម៉ាស៊ីនទី១ : អានុភាពតម្លើង 100 kW
- ម៉ាស៊ីនទី២ : អានុភាពតម្លើង 100 kW
- ម៉ាស៊ីនទី៣ : អានុភាពតម្លើង 200 kW
- ម៉ាស៊ីនទី៤ : អានុភាពតម្លើង 250 kW
- ម៉ាស៊ីនទី៥ : អានុភាពតម្លើង 320 kW

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងដ្យេសែល ។

#### គ. ការស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម

១-ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ពេលនោះអ្នកកាន់ អាជ្ញាប័ណ្ណត្រូវរៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចអនុញ្ញាតឱ្យផ្លាស់ប្តូរ ឬបន្ថែមមធ្យោបាយផលិតកម្ម ឧបសម្ព័ន្ធទី២នេះត្រូវធ្វើការកែសម្រួល ដោយភ្ជាប់ជាមួយសេចក្តីសម្រេចឱ្យផ្លាស់ប្តូរឬបន្ថែមមធ្យោបាយផលិតកម្មនោះ ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ។ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។